កិច្ចប្រជុំកំពូលលើកទី២០ របស់ប្រមុខរដ្ឋនិងប្រមុខរដ្ឋាភិបាល
នៃបណ្តាប្រទេសប្រើប្រាស់ភាសាបារាំង

ភ្នំពេញ (កម្ពុជា) ថ្ងៃទី១៥ និង១៦ ខែវិច្ឆិកា ឆ្នាំ២០២៦

សេចក្តីសម្រេចស្តីពីស្ថានភាពវិបត្តិ ស្ថានភាពចាកចេញពីវិបត្តិ និងស្ថានភាពពង្រឹងសន្តិភាពនៅក្នុងលំហហ្វ្រង់កូហ្វូនី

បុព្វកថា

យើង ជាប្រមុខដ្ឋ និងប្រមុខរដ្ឋាភិបាលនៃបណ្តាប្រទេសប្រើប្រាស់ភាសាបារាំង បានជួបប្រជុំគ្នានៅថ្ងៃទី១៥ និងទី ១៦ ខែវិច្ឆិកា ឆ្នាំ២០២៦ នៅទីក្រុងភ្នំពេញ (ព្រះរាជាណាចក្រកម្ពុជា) ក្នុងឱកាសកិច្ចប្រជុំកំពូលហ្វ្រង់កូហ្វូនីលើកទី២០ ក្រោមមូលបទ **«រួមគ្នាបន្តកសាងសន្តិភាព ដើម្បីវិបុលភាពរួម និងស្ថិរភាពយូរអង្វែង»** ;

ដោយបញ្ជាក់ជាថ្មី នូវការគោរពរបស់យើងចំពោះគោលការណ៍សកលនៃច្បាប់អន្តរជាតិ ជាពិសេសគោលការណ៍ដែលមានចែងក្នុងធម្មនុញ្ញអង្គការសហប្រជាជាតិ និងធម្មនុញ្ញអន្តរជាតិស្តីពីសិទ្ធិមនុស្ស ព្រមទាំងការប្រកាន់ខ្ជាប់របស់យើងចំពោះពហុភាគីនិយម តម្លៃនៃសន្តិភាពនិងសាមគ្គីភាព សិទ្ធិមនុស្សនិងសេរីភាពជាមូលដ្ឋាន; **ដោយបញ្ជាក់ជាថ្មី** នូវការប្រកាន់ខ្ជាប់របស់យើងចំពោះគោលការណ៍នៃអធិបតេយ្យភាព និងបូរណភាពទឹកដី ដែលការរំលោភលើគោលការណ៍ទាំងនេះនឹងធ្វើឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សន្តិភាព និងសន្តិសុខ; **ដោយបញ្ជាក់ជាថ្មីម្តងទៀត** នូវភាពចាំបាច់ក្នុងការគោរពច្បាប់អន្តរជាតិ ជាពិសេសសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ និងសាលក្រមរបស់តុលាការយុត្តិធម៌អន្តរជាតិ ហើយក្នុងករណីសមស្រប យើងប្តេជ្ញាចិត្តអនុវត្តតាមអនុសាសន៍ណែនាំរបស់តុលាការយុត្តិធម៌អន្តរជាតិ ពាក់ព័ន្ធនឹងស្ថានភាពវិបត្តិ និងជម្លោះនៅក្នុងលំហហ្វ្រង់កូហ្វូនី;

ដោយបញ្ជាក់ជាថ្មីផងដែរ នូវការប្រកាន់ខ្ជាប់របស់យើងចំពោះហ្វ្រង់កូហ្វូនី គុណតម្លៃ ភាពចំរុះ និងលក្ខណៈពិសេសរបស់ហ្វ្រង់កូហ្វូនី ក្នុងនាមជាវេទិកាសម្រាប់កិច្ចសន្ទនា សាមគ្គីភាព និងកិច្ចសហប្រតិបត្តិការ;

ដោយរំឭកឡើងវិញ នូវភាពចាំបាច់នៃការគោរពធម្មនុញ្ញរបស់ហ្វ្រង់កូហ្វូនី សេចក្តីថ្លែងការណ៍ទីក្រុងបាម៉ាកូ និងសេចក្តីថ្លែងការណ៍ទីក្រុងសាំងបូនីហ្វាស ដែលជាមូលដ្ឋានគ្រឹះនៃសកម្មភាពរបស់អង្គការអន្តរជាតិហ្វ្រង់កូហ្វូនីដើម្បីសន្តិភាព ស្ថិរភាពនិងសន្តិសុខ ការពង្រឹងពង្រីកលទ្ធិប្រជាធិបតេយ្យនិងនីតិរដ្ឋ ការបង្ការ ការគ្រប់គ្រង និងការដោះស្រាយវិបត្តិ ជម្លោះ ព្រមទាំងសិទ្ធិមនុស្ស ;

ដោយបញ្ជាក់ជាថ្មី នូវការប្តេជ្ញាចិត្តរបស់យើងក្នុងការទប់ស្កាត់ និងការប្រយុទ្ធប្រឆាំងមនោគមវិជ្ជាជ្រុលនិយមប្រកបដោយហិង្សា និងភាពជ្រុលនិយម ហើយនិងឆន្ទៈរបស់យើងក្នុងការការពារប្រជាជនទប់ទល់នឹងអំពើភេរវកម្មដែលកើតមាននៅគ្រប់ទ្វីបទាំងអស់ ;

ដោយបញ្ជាក់ជាថ្មី នូវការថ្កោលទោសរបស់យើងចំពោះការរំលោភបំពានសណ្តាប់ធ្នាប់ធម្មនុញ្ញ និងប្រជាធិបតេយ្យ នៅក្នុងលំហហ្វ្រង់កូហ្វូនី ជាអាទិ៍ រដ្ឋប្រហារយោធា; **ដោយរឭក** ក្នុងន័យនេះ អំពីកិច្ចប្រជុំលើកទី១២៧ នៃក្រុមប្រឹក្សាអចិន្ត្រៃយ៍ហ្វ្រង់កូហ្វូនី (CPF) កាលពីថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២៤ ដែលបានអនុម័ត «យន្តការតាមដាន និងវាយតម្លៃស្ថានភាពរបស់រដ្ឋ និងរដ្ឋាភិបាលដែលស្ថិតក្រោមវិធានការរបស់ស្ថាប័ននានានៃហ្វ្រង់កូហ្វូនី» ដែលទាំងនេះឆ្លុះបញ្ចាំងពីឆន្ទៈរបស់អង្គការអន្តរជាតិហ្វ្រង់កូហ្វូនី ក្នុងការផ្តល់អាទិភាពដល់កិច្ចសន្ទនាជាមួយបណ្តាប្រទេសរងការបែកបាក់លទ្ធិប្រជាធិបតេយ្យ ជាជាងការព្យួរសមាជិកភាពដោយស្វ័យប្រវត្តិ ដើម្បីរក្សាភាពប្រុងប្រយ័ត្នរបស់យើងចំពោះផលប្រយោជន៍របស់ប្រជាជន;

ដោយសោកស្តាយយ៉ាងខ្លាំង ចំពោះផលវិបាកនានាបង្កឡើងដោយវិបត្តិនិងជម្លោះមកលើមនុស្ស សង្គម សេដ្ឋកិច្ច សន្តិសុខ បរិស្ថាន និងអភិបាលកិច្ច ដោយរួមទាំងការផ្លាស់ទីលំនៅដោយបង្ខំរបស់ប្រជាជន ភាពផុយស្រួយនៃស្ថាប័ន ការបាត់បង់ទំនុកចិត្តរបស់ប្រជាពលរដ្ឋទៅលើរដ្ឋ និងការកើនឡើងនៃភាពងាយរងគ្រោះរបស់រដ្ឋ; **ដោយបង្ហាញ**ទឹកចិត្តសាមគ្គីភាពជាមួយជនរងគ្រោះទាំងអស់;

ដោយមានការព្រួយបារម្ភ ចំពោះហានិភ័យនៃការពង្រីកវិបត្តិនិងជម្លោះយុគសម័យថ្មី តាមរយៈការឃោសនាផ្សព្វផ្សាយភាពស្អប់ខ្ពើម និងតាមរយៈការប្រើប្រាស់បច្ចេកវិទ្យាថ្មីៗ; **ដោយមានការព្រួយបារម្ភ**ផងដែរ ចំពោះការគំរាមកំហែងដល់សន្តិភាពនិងស្ថិរភាពអន្តរជាតិ និងចំពោះការប្រើប្រាស់បញ្ញាសិប្បនិម្មិតក្នុងគោលបំណងអាក្រក់ ដើម្បីធ្វើឱ្យយុទ្ធនាការបំភាន់ព័ត៌មាន និងការជ្រៀតជ្រែកពីបរទេសកាន់តែមានល្បឿនលឿននិងស្មុគស្មាញ; **ដោយអំពាវនាវ**អង្គការអន្តរជាតិហ្វ្រង់កូហ្វូនី ឱ្យពង្រឹងកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនចូលរួមបង្ការប្រយុទ្ធប្រឆាំងនឹងបាតុភាពទាំងនេះ ដោយអនុលោមតាមច្បាប់អន្តរជាតិ;

ដោយគូសបញ្ជាក់ អំពីតួនាទីដ៏សំខាន់របស់ស្ត្រីនិងយុវជន, អង្គការសង្គមស៊ីវិលនិងអង្គការមិនមែនរដ្ឋាភិបាល, អង្គការជើងនាំសាសនានិងប្រពៃណី, ព្រមទាំងអ្នកទទួលបន្ទុកបង្ការជម្លោះនិងពង្រឹងសន្តិភាព ; **ដោយរឭក** ក្នុងន័យនេះ អំពីសេចក្តីសម្រេចលេខ១៣២៥ (ឆ្នាំ២០០០) របស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ព្រមទាំងសេចក្តីអំពាវនាវទីក្រុងគីហ្គាលី ដែលត្រូវបានអនុម័តនៅក្នុងកិច្ចប្រជុំលើកទី៤៦ នៃសន្និសីទថ្នាក់រដ្ឋមន្ត្រីនៃហ្វ្រង់កូហ្វូនី (CMF) នាទីក្រុងគីហ្គាលី ប្រទេសរវ៉ាន់ដា កាលពីថ្ងៃទី១៩ និងទី២០ ខែវិច្ឆិកា ឆ្នាំ២០២៥ ដែលតាមរយៈសេចក្តីអំពាវនាវនេះ អង្គការអន្តរជាតិហ្វ្រង់កូហ្វូនីបានបញ្ជាក់ជាថ្មីពីសារៈសំខាន់នៃការចូលរួមរបស់ស្ត្រីនៅគ្រប់ដំណាក់កាលនៃដំណើរការសន្តិភាព រួមទាំងការបង្ការ និងការគ្រប់គ្រងជម្លោះ ការសម្រុះសម្រួល ការចរចា និងការស្តារប្រទេសឡើងវិញបន្ទាប់ពីជម្លោះ;

ដោយបញ្ជាក់អះអាងជាថ្មី អំពីឆន្ទៈរបស់យើងក្នុងការពង្រឹងកិច្ចសហប្រតិបត្តិការ និងការសម្របសម្រួលរបស់ហ្វ្រង់កូហ្វូនីជាមួយអង្គការអន្តរជាតិនិងតំបន់ ដោយគោរពទៅតាមសមត្ថកិច្ចរៀងៗខ្លួន ដើម្បីបង្កើនប្រសិទ្ធភាពនៃសកម្មភាពនានាក្នុងការលើកកម្ពស់សន្តិភាព និងស្ថិរភាព ;

ដោយបញ្ជាក់ជាថ្មី អំពីការគាំទ្ររបស់យើងចំពោះប្រតិបត្តិការសន្តិភាពក្រោមឆត្ររបស់អង្គការសហប្រជាជាតិ និងប្រតិបត្តិការថែរក្សាសន្តិភាព; **ដោយផ្តោតសារៈសំខាន់** លើការពិចារណាដែលកំពុងប្រព្រឹត្តទៅ ពាក់ព័ន្ធនឹងកំណែទម្រង់និងអនាគតនៃប្រតិបត្តិការសន្តិភាពព្រមទាំងប្រតិបត្តិការថែរក្សាសន្តិភាពទាំងនេះ; **ដោយស្វាគមន៍និងលើក**

ទឹកចិត្ត ចំពោះការចូលរួមរបស់រដ្ឋ និងរដ្ឋាភិបាលសមាជិកហ្វ្រង់កូហ្វូនី និងអង្គការអន្តរជាតិហ្វ្រង់កូហ្វូនី នៅក្នុងប្រតិបត្តិការទាំងនេះ ជាអាទិ៍តាមរយៈការគាំទ្រដល់បណ្តាប្រទេសប្រើប្រាស់ភាសាបារាំង ដែលចូលរួមបញ្ជូនទ័ពនិងកងកម្លាំងនគរបាល ជាពិសេសកងកម្លាំងសម្រាប់ជួយផ្នែកបណ្តុះបណ្តាល ផ្នែកពង្រឹងសមត្ថភាព និងផ្នែករៀបចំជាក់ពង្រាយកងកម្លាំង; **ដោយសម្តែង** នូវឆន្ទៈរបស់យើងក្នុងការបន្ត និងពង្រឹងការគាំទ្រការងារទាំងអស់នេះ;

ដោយស្វាគមន៍ ចំពោះការរៀបចំសន្និសីទថ្នាក់រដ្ឋមន្ត្រីលើកទី២ ស្តីពីការរក្សាសន្តិភាពក្នុងលំហហ្វ្រង់កូហ្វូនី នៅទីក្រុងរ៉ាបាត ប្រទេសម៉ារ៉ុក នាថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២៦ សហការរៀបចំដោយម៉ារ៉ុកនិងបារាំង អង្គការសហប្រជាជាតិ និងអង្គការអន្តរជាតិហ្វ្រង់កូហ្វូនី ដែលសេចក្តីថ្លែងការណ៍ចុងក្រោយនៃសន្និសីទនេះ បានបញ្ជាក់ជាថ្មីនូវការប្តេជ្ញាចិត្តរបស់បណ្តារដ្ឋនានា ក្នុងការលើកកម្ពស់សន្តិភាព សន្តិសុខ និងការអភិវឌ្ឍរួមគ្នា;

ដោយរឭកថា ជំណោះស្រាយប្រកបដោយចីរភាពនៃវិបត្តិនិងជម្លោះនានា ត្រូវតែផ្តើមចេញពីខាងក្នុង ដោយផ្អែកលើការយល់ដឹងអំពីស្ថានភាពជាក់ស្តែងនៅមូលដ្ឋាន និងស្របតាមច្បាប់អន្តរជាតិ ដោយគិតគូរដល់កត្តាសេដ្ឋកិច្ច សង្គម បរិស្ថាន និងព្រំដែន ដែលអាចចិញ្ចឹមឬអូសបន្លាយវិបត្តិនិងជម្លោះទាំងនេះ; **ដោយគូសបញ្ជាក់** អំពីសារៈសំខាន់នៃការពង្រឹងសកម្មភាពរបស់អង្គការអន្តរជាតិហ្វ្រង់កូហ្វូនី ក្នុងការបង្ការនិងគ្រប់គ្រងវិបត្តិ ការគាំទ្រដំណើរការសន្តិភាព ជាអាទិ៍តាមរយៈការសម្រុះសម្រួលនិងការគាំទ្រអន្តរកាលប្រជាធិបតេយ្យ ដោយពឹងផ្អែកបន្ថែមលើលទ្ធផលវិភាគនៃមជ្ឈមណ្ឌលស្រាវជ្រាវរបស់ហ្វ្រង់កូហ្វូនី;

ដោយស្វាគមន៍ ចំពោះការប្តេជ្ញាចិត្តជាប់ជាប្រចាំរបស់អគ្គលេខាធិការ ; **ដោយគូសបញ្ជាក់** ពីតួនាទីរបស់អង្គការអន្តរជាតិហ្វ្រង់កូហ្វូនី ក្នុងការបង្ការនិងគ្រប់គ្រងវិបត្តិនៅក្នុងលំហហ្វ្រង់កូហ្វូនី; និង**ដោយលើកទឹកចិត្ត**អង្គការអន្តរជាតិហ្វ្រង់កូហ្វូនីឱ្យបន្តគំនិតផ្តួចផ្តើមផ្សេងៗ ពាក់ព័ន្ធនឹងកិច្ចសម្រុះសម្រួលនិងកិច្ចសន្ទនានយោបាយ តាមរយៈកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយរដ្ឋនិងរដ្ឋាភិបាលពាក់ព័ន្ធ;

ដោយផ្អែកលើសេចក្តីថ្លែងការណ៍នៃកិច្ចប្រជុំកំពូលហ្វ្រង់កូហ្វូនីលើកទី២០;

ដោយសម្រេចសម្រួចកិច្ចខិតខំប្រឹងប្រែងរបស់យើង ដើម្បីបុព្វហេតុសន្តិភាពនិងស្ថិរភាព ការពង្រឹងលទ្ធិប្រជាធិបតេយ្យ និងនីតិរដ្ឋនៅក្នុងលំហហ្វ្រង់កូហ្វូនី;

អាមេនី

1. **យើងគាំទ្រ**វឌ្ឍនភាពសម្រេចបានដោយអាមេនី និងអាស៊ែបៃហ្សង់ ក្នុងដំណើរការធ្វើឱ្យទំនាក់ទំនងរវាងប្រទេសទាំងពីរវិលមករកប្រក្រតីភាពឡើងវិញ; ក្នុងន័យនេះ **យើងសូមស្វាគមន៍** ចំពោះការចុះហត្ថលេខាលើសេចក្តីថ្លែងការណ៍រួមនៃកិច្ចប្រជុំកំពូលសន្តិភាព នៅទីក្រុងវ៉ាស៊ីនតោន កាលពីថ្ងៃទី៨ ខែសីហា ឆ្នាំ២០២៥ និងការចុះហត្ថលេខាបឋមលើកិច្ចព្រមព្រៀងស្តីពីការកសាងសន្តិភាពនិងទំនាក់ទំនងអន្តរដ្ឋរវាងសាធារណរដ្ឋអាមេនី និងសាធារណរដ្ឋអាស៊ែបៃហ្សង់ ;

2. **យើងលើកទឹកចិត្ត**ឱ្យបន្តកិច្ចសន្ទនាបែបស្ថាបនា ពាក់ព័ន្ធនឹងគំនិតផ្តួចផ្តើមនានា ដើម្បីអភិវឌ្ឍការតភ្ជាប់តំបន់ប្រកបដោយសមធម៌ បរិយាបន្ន តម្លៃសមមូ្យ និងកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច ជាអាទិ៍គំនិតផ្តួចផ្តើម «ផ្លូវបំបែកនៃសន្តិភាព» និងគម្រោង TRIPP ; **យើងស្វាគមន៍** កិច្ចខិតខំប្រឹងប្រែងនានាដើម្បីបើកព្រំដែនឡើងវិញរវាងប្រទេសអាមេនី និងតួគីយេ ;

3. **យើងបញ្ជាក់អះអាងជាថ្មី** អំពីការគាំទ្ររបស់យើងចំពោះដំណើរការខណ្ឌសីមានិងការបោះបង្គោលព្រំដែនអន្តរដ្ឋ ដោយឈរលើមូលដ្ឋាននៃការទទួលស្គាល់ទៅវិញទៅមកនូវអធិបតេយ្យភាពនិងបូរណភាពទឹកដីស្របតាមសេចក្តីថ្លែងការណ៍ទីក្រុងអាល់ម៉ា-អាតា (Alma-Ata) ឆ្នាំ១៩៩១ ;

4. **យើងទទួលស្គាល់ថា** ការដោះស្រាយបញ្ហាមនុស្សធម៌ដែលនៅសេសសល់ រួមទាំងការដោះលែងអ្នកដែលត្រូវបានឃុំខ្លួន ព្រមទាំងការផ្តល់ព័ត៌មានពន្យល់បំភ្លឺអំពីជោគវាសនារបស់មនុស្សបាត់ខ្លួន និងករណីបាត់ខ្លួនដោយបង្ខំ នឹងរួមចំណែកដល់ការពង្រឹងទំនាក់ទំនងប្រកបដោយទំនុកចិត្ត ;

5. **យើងកោតសរសើរ** ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាលអាមេនី ដោយមានការគាំទ្រពីបណ្តាដៃគូអន្តរជាតិ ក្នុងការធ្វើសមាហរណកម្មជនភៀសខ្លួនអាមេនី ដែលបានផ្លាស់ទីលំនៅចេញពីតំបន់ការ៉ាបាក់ (Karabakh) ទៅក្នុងស្រទាប់សង្គម សេដ្ឋកិច្ច និងវប្បធម៌អាមេនី ហើយយើងក៏សូម**គូសបញ្ជាក់**អំពីសារៈសំខាន់នៃការបន្តកិច្ចខិតខំប្រឹងប្រែងទាំងនេះ ;

6. **យើងស្វាគមន៍** ចំពោះវឌ្ឍនភាពសម្រេចបានក្នុងក្របខ័ណ្ឌនៃដំណើរការលើកកម្ពស់ប្រជាធិបតេយ្យការិបនីយកម្ម និងការពង្រឹងស្ថាប័ននានា ព្រមទាំងកិច្ចខិតខំប្រឹងប្រែងប្រយុទ្ធប្រឆាំងនឹងការជ្រៀតជ្រែកពីបរទេស ការគំរាមកំហែងបែបអ៊ីប្រ៊ីដ (hybride) និងយុទ្ធនាការព័ត៌មានក្លែងក្លាយ; ក្នុងន័យនេះ **យើងទទួលដឹងឮ** អំពីដំណើរការប្រព្រឹត្តទៅដោយរលូននៃការបោះឆ្នោតសភា កាលពីថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០២៦ ដែលស្តែងឱ្យឃើញនូវភាពធន់និងសមត្ថភាពនៃបណ្តាស្ថាប័ន ក្នុងការធានាបាននូវដំណើរការបោះឆ្នោតដោយសេរីតម្លាភាព និងគួរឱ្យជឿទុកចិត្ត ទោះបីជាមានបញ្ហាប្រឈមខ្លះក៏ដោយ; **យើងរំឭកសាជាថ្មី** អំពីការប្តេជ្ញាចិត្តរបស់ហ្វ្រង់កូហ្វូនី ក្នុងការគាំទ្រប្រទេសអាមេនីដើម្បីពង្រឹងសមត្ថភាពស្ថាប័ន ការលើកកម្ពស់នីតិរដ្ឋ លទ្ធិប្រជាធិបតេយ្យ និងព័ត៌មានគ្រប់ជ្រុងជ្រោយ;

<u>កម្ពុជា</u>

7. **យើងសម្តែងការព្រួយបារម្ភ**របស់យើង ចំពោះភាពតានតឹងរ៉ាំរ៉ៃនៅតាមតំបន់ព្រំដែនកម្ពុជា-ថៃ; **យើងបញ្ជាក់អះអាងជាថ្មី** អំពីការគាំទ្ររបស់យើងចំពោះអធិបតេយ្យភាពនិងបូរណភាពទឹកដីរបស់ព្រះរាជាណាចក្រកម្ពុជា;

8. **យើងសំដែងការសោកស្តាយ** ចំពោះទុក្ខវេទនារបស់ប្រជាជនដែលត្រូវផ្លាស់ទីលំនៅដោយបង្ខំ ជាពិសេសប្រជាជនកម្ពុជា; **យើងគូសបញ្ជាក់** អំពីសារៈសំខាន់នៃការធានាការពារប្រជាជនស៊ីវិលរងគ្រោះដោយភាពតានតឹងនៅតាមព្រំដែន ស្របតាមច្បាប់អន្តរជាតិ; **យើងអំពាវនាវ**ឱ្យមានការធានាថា ប្រជាជនដែលត្រូវផ្លាស់ទីលំនៅនិងសហគមន៍ដែលរងផលប៉ះពាល់ អាចទទួលបានជំនួយមនុស្សធម៌និងសេវាចាំបាច់ជាមូលដ្ឋាននានាប្រកបដោយសុវត្ថិភាពនិងដោយគ្មានការរារាំង ព្រមទាំងធានាការការពារសិទ្ធិរបស់ពួកគេក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅ និងត្រូវលុបបំបាត់ឧបសគ្គ ព្រមទាំងបង្កើតលក្ខខណ្ឌអំណោយផលដើម្បីឱ្យពួកគេពិតជាអាចវិលត្រឡប់ទៅកាន់លំនៅដ្ឋានដើមវិញ ប្រកបដោយសុវត្ថិភាព ដោយស្ម័គ្រចិត្ត និងដោយយូរអង្វែង;

9. **យើងគូសបញ្ជាក់ថា** រាល់វិវាទព្រំដែនត្រូវតែដោះស្រាយដោយមធ្យោបាយសន្តិវិធីតែមួយមុខប៉ុណ្ណោះ ស្របតាមច្បាប់អន្តរជាតិ ហើយមិនអាចមានការផ្លាស់ប្តូរខ្សែបន្ទាត់ព្រំដែនណាមួយតាមរយៈការប្រើប្រាស់កម្លាំង

ឬតាមរយៈការបង្កើតស្ថានភាពជាក់ស្តែងនៅលើដី (faits accomplis) នោះឡើយ

10. **យើងទទួលដឹងឮ** អំពីកិច្ចខិតខំប្រឹងប្រែងអនុវត្តរួមគ្នាដើម្បីបន្ធូរបន្ថយភាពតានតឹងនៅតាមព្រំដែន; ក្នុងន័យនេះ **យើងអំពាវនាវ** ឱ្យមានការអនុវត្តនូវអ្វីដែលបានព្រមព្រៀងគ្នានៅក្នុងសេចក្តីថ្លែងការណ៍រួម ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២៥ ពាក់ព័ន្ធជាអាទិ៍ ការចាប់ផ្តើមឡើងវិញឱ្យបានឆាប់ហើសបំផុតនូវការងារវាស់វែងនិងបោះបង្គោលព្រំដែនរបស់**គណៈកម្មការចម្រុះខណ្ឌសីមាព្រំដែនគោក** (JBC); **យើងគូសបញ្ជាក់ថា** ការងារទាំងនេះត្រូវអនុវត្តស្របតាមកិច្ចព្រមព្រៀងទាំងអស់ដែលមានស្រាប់;

11. **យើងអំពាវនាវដោយទទូច** ឱ្យភាគីទាំងសងខាងគោរពបទឈប់បាញ់ឱ្យបានពេញលេញ និងជៀសវាងរាល់សកម្មភាពដែលអាចបង្កឱ្យមានភាពតានតឹងឡើងវិញ ឬធ្វើឱ្យប៉ះពាល់ដល់ការងារខណ្ឌសីមានិងបោះបង្គោលព្រំដែន; **យើងស្វាគមន៍** រាល់គំនិតផ្តួចផ្តើមរបស់តំបន់ ក្នុងគោលដៅកាត់បន្ថយភាពតានតឹង និងស្តារទំនុកចិត្តឡើងវិញ; **យើងលើកទឹកចិត្ត** ឱ្យបន្តកិច្ចសន្ទនានិងប្រើប្រាស់មធ្យោបាយដោះស្រាយវិវាទដោយសន្តិវិធីស្របតាមច្បាប់អន្តរជាតិ ជាអាទិ៍**នីតិវិធីការផ្សះផ្សាដោយបង្ខំក្រោមអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីនីតិសមុទ្រ** ឆ្នាំ១៩៨២ សម្រាប់ការដោះស្រាយវិវាទដែនសមុទ្រ;

<u>សាធារណរដ្ឋអាហ្វ្រិកកណ្តាល</u>

12. **យើងនៅតែព្រួយបារម្ភ** អំពីបញ្ហាប្រឈមផ្នែកសន្តិសុខនិងមនុស្សធម៌ ដែលបន្តកើតមាននៅតំបន់មួយចំនួននៃប្រទេស ព្រមទាំងផលប៉ះពាល់ឆ្លងព្រំដែននៃជម្លោះនៅប្រទេសស៊ូដង់ ទៅដល់សាធារណរដ្ឋអាហ្វ្រិកកណ្តាលផងដែរ ;

13. **យើងទទួលដឹងឮ** អំពីការរៀបចំឱ្យមានវដ្តនៃការបោះឆ្នោតឆ្នាំ២០២៥-២០២៦ ហើយ**យើងលើកទឹកចិត្ត** ឱ្យមានកិច្ចខិតខំប្រឹងប្រែងបន្តទៀត ដើម្បីពង្រឹងសន្តិភាព ពង្រឹងស្ថាប័នប្រជាធិបតេយ្យនិងពង្រីកអំណាចរបស់រដ្ឋឱ្យគ្របដណ្តប់ទូទាំងប្រទេស ;

14. **យើងស្វាគមន៍** កិច្ចខិតខំប្រឹងប្រែងរបស់អង្គការសហប្រជាជាតិ ក្នុងក្របខ័ណ្ឌនៃការប្រមូលផ្តុំបេសកកម្មពហុវិស័យរបស់អង្គការសហប្រជាជាតិ ដើម្បីរក្សាស្ថិរភាពនៅសាធារណរដ្ឋអាហ្វ្រិកកណ្តាល (MINUSCA) ;

15. **យើងអំពាវនាវ** ឱ្យមានការបន្តកិច្ចសន្ទនា និងកិច្ចសហប្រតិបត្តិការជាមួយដៃគូក្នុងតំបន់ និងអន្តរជាតិ ;

<u>ស៊ីប</u>

16. **យើងគាំទ្រ** ការចាប់ផ្តើមចរចាឡើងវិញ ក្រោមការសម្របសម្រួលរបស់អង្គការសហប្រជាជាតិ ដើម្បីស្វែងរកដំណោះស្រាយប្រកបដោយចីរភាព គ្រប់ជ្រុងជ្រោយ និងយុត្តិធម៌សម្រាប់ប្រទេសស៊ីប ស្របតាមសេចក្តីសម្រេចនានារបស់អង្គការសហប្រជាជាតិ និងដើម្បីបង្រួបបង្រួមប្រទេសនិងប្រជាជនស៊ីប ក៏ដូចជាស្ថាប័ននៃប្រទេសនេះឡើងវិញ ;

17. **យើងស្នើ** ឱ្យមានការអនុវត្តសេចក្តីសម្រេចពាក់ព័ន្ធនានារបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ជាពិសេសសេចក្តីសម្រេចលេខ១២៥១ (១៩៩៩) ព្រមទាំងសេចក្តីសម្រេចពាក់ព័ន្ធផ្សេងទៀត ដែលទាក់ទង

នឹងលក្ខន្តិក:ពិសេសនៃតំបន់វ៉ារ៉ូសា(Varosha) ដើម្បីឈានទៅដល់ការបង្កើតរដ្ឋស៊ីបមួយដែលមានអធិបតេយ្យភាព បុគ្គលិកលក្ខណៈអន្តរជាតិ និងជារដ្ឋដែលមានសញ្ជាតិតែមួយ ព្រមទាំងមានការធានានូវបូរណភាពទឹកដី ឯករាជ្យភាព និងមានសហគមន៍ពីរដែលមានសមភាពផ្នែកនយោបាយ ដូចមានពិពណ៌នាក្នុងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ និងត្រូវរៀបចំឡើងក្នុងទម្រង់ជាសហព័ន្ធដែលមានសហគមន៍ពីរ និងតំបន់ពីរ ដោយមិនរាប់បញ្ចូលទម្រង់នៃការបែងចែកទឹកដី ឬការរួមបញ្ចូលគ្នាជាមួយប្រទេសផ្សេងទៀត ហើយដំណោះស្រាយនោះត្រូវតែស្របតាមច្បាប់សហគមន៍សហភាពអឺរ៉ុប ដែលប្រទេសស៊ីបជាសមាជិក;

18. **យើងស្វាគមន៍** ចំពោះកិច្ចខិតខំប្រឹងប្រែងថ្មីៗរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិ ក្នុងគោលបំណងឱ្យមានការចាប់ផ្តើមកិច្ចចរចាឡើងវិញ នៅក្នុងក្របខ័ណ្ឌរបស់អង្គការសហប្រជាជាតិ;

កុងហ្គោ (សាធារណរដ្ឋប្រជាធិបតេយ្យ)

19. **យើងបន្តព្រួយបារម្ភ** ចំពោះស្ថានភាពសន្តិសុខ និងស្ថានភាពមនុស្សធម៌នៅភាគខាងកើតនៃសាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោ (RDC) ដែលកំពុងប្រឈមនឹងអំពើហិង្សាជាបន្តបន្ទាប់លើប្រជាជនស៊ីវិល ការបង្ខំឱ្យផ្លាស់ទីលំនៅ ការរំលោភសិទ្ធិមនុស្សនិងច្បាប់អន្តរជាតិ ព្រមទាំងផលប៉ះពាល់ផ្នែកសុខភាព ជាពិសេសការរីករាលដាលនៃវីរុសអេបូឡា។ ក្នុងន័យនេះ **យើងអំពាវនាវ** ឱ្យគ្រប់ភាគី គោរពឱ្យបានពេញលេញនូវកាតព្វកិច្ចរបស់ខ្លួន ស្របតាមច្បាប់អន្តរជាតិ ជាពិសេសច្បាប់មនុស្សធម៌អន្តរជាតិ ;

20. **យើងថ្កោលទោស** អំពើហិង្សា និងការញុះញង់ឱ្យមានអំពើហិង្សា ដែលប្រព្រឹត្តដោយក្រុមប្រដាប់អាវុធ ជាពិសេសការប្រើអំពើរំលោភសេពសន្តវៈជាអាវុធសង្គ្រាម ការបង្ខំយុវជនឱ្យចូលរួមក្នុងជម្លោះ ការប្រើប្រាស់កុមារជាទាហាន និងការបំផ្លិចបំផ្លាញតំបន់ការពារធម្មជាតិនៅអាងទន្លេកុងហ្គោ ; **យើងទាមទារ** ឱ្យបញ្ឈប់រាល់ការគាំទ្រផ្នែកនយោបាយ យោធា ហិរញ្ញវត្ថុ និងកស្តុការដល់ក្រុមប្រដាប់អាវុធ រុះរើរដ្ឋបាលខុសច្បាប់ដែលដំណើរការស្របគ្នានឹងរដ្ឋ និងស្តារអំណាចរដ្ឋឡើងវិញ; **យើងអំពាវនាវ** ឱ្យគោរពការប្តេជ្ញាចិត្តដែលបានព្រមព្រៀងគ្នា ក្នុងក្របខ័ណ្ឌនៃដំណើរការទីក្រុងដូហា និងកិច្ចព្រមព្រៀងសន្តិភាពទីក្រុងវ៉ាស៊ីនតោន ព្រមទាំងធានាឱ្យជនផ្លាស់ទីលំនៅអាចវិលត្រឡប់ទៅកាន់លំនៅឋានដើមរបស់ខ្លួនវិញដោយស្ម័គ្រចិត្ត សុវត្ថិភាព និងសេចក្តីថ្លៃថ្នូរ ;

21. **យើងបញ្ជាក់ជាថ្មី** នូវការប្តេជ្ញាចិត្តរបស់យើងក្នុងការគោរពអធិបតេយ្យភាព ឯករាជ្យភាព ឯកភាពនិង**បូរណភាព**ទឹកដីរបស់សាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោ ព្រមទាំងគោលការណ៍មិនអាចកែប្រែបាននៃព្រំដែនរបស់ប្រទេសនេះ ដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិ ;

22. **យើងទទួលស្គាល់** ថាសកម្មភាពអាជីវកម្ម និងពាណិជ្ជកម្មខុសច្បាប់លើធនធានធម្មជាតិ បានរួមចំណែកផ្តល់ហិរញ្ញប្បទានដល់ក្រុមប្រដាប់អាវុធ និងអូសបន្លាយជម្លោះ ; **យើងថ្កោលទោស** ចំពោះបណ្តាញឧក្រិដ្ឋកម្មជាប្រព័ន្ធ ដែលគាំទ្រដល់ការនាំចេញធនធានធម្មជាតិទាំងនេះដោយខុសច្បាប់ទៅកាន់ប្រទេសគោលដៅ ឬប្រទេសឆ្លងកាត់ ; **យើងលើកទឹកចិត្ត** ឱ្យពង្រឹងការតាមដានប្រកពដើម និងតម្លាភាពក្នុងខ្សែចង្វាក់ផ្គត់ផ្គង់ធនធានធម្មជាតិ ដើម្បីប្រែក្លាយធនធានទាំងនេះទៅជាកម្លាំងចលករសម្រាប់ការអភិវឌ្ឍ និងការពង្រឹងសន្តិភាព ;

23. **យើងស្វាគមន៍** គំនិតផ្តួចផ្តើមសន្តិភាពនានានៅកម្រិតតំបន់និងអន្តរជាតិ ជាពិសេសគំនិតផ្តួចផ្តើមដឹកនាំដោយសហភាពអាហ្វ្រិក ព្រមទាំងកិច្ចព្រមព្រៀងសន្តិភាពទីក្រុងវ៉ាស៊ីនតោន និងអភិក្រមទីក្រុងដូហា ; **យើងអំពាវនាវ** ឱ្យអនុវត្តឱ្យបានពេញលេញនូវការប្តេជ្ញាចិត្តដែលបានព្រមព្រៀងគ្នា ហើយ**យើងគូសបញ្ជាក់ថា** ការគោរពការប្តេជ្ញាចិត្តទាំងនេះ រួមនិងការអនុវត្តសេចក្តីសម្រេចពាក់ព័ន្ធទាំងអស់របស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ គឺជាកត្តាចាំបាច់សម្រាប់ការស្តារសន្តិភាពប្រកបដោយចីរភាពនៅក្នុងតំបន់ឡើងវិញ;

24. **យើងគាំទ្រ** កិច្ចខិតខំប្រឹងប្រែងរបស់អង្គការអន្តរជាតិហ្វ្រង់កូហ្វូនី នៅក្នុងក្របខ័ណ្ឌនៃដែនសមត្ថកិច្ចនិងកម្មវិធីរបស់ខ្លួន ; ក្នុងន័យនេះ **យើងស្វាគមន៍**ការបញ្ជូនបេសកកម្មប្រមូលព័ត៌មានដោយ**អគ្គលេខាធិការហ្វ្រង់កូហ្វូនី** កាលពីខែមិថុនា ឆ្នាំ២០២៥ ទៅតាមការអំពាវនាវរបស់សាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោ (RDC) ដែលបានស្នើឱ្យហ្វ្រង់កូហ្វូនីបង្ហាញសាមគ្គីភាពចំពោះស្ថានភាពនៅភាគខាងកើតនៃប្រទេសកុងហ្គោ ព្រមទាំងបានស្នើឱ្យហ្វ្រង់កូហ្វូនីគាំទ្រដល់កិច្ចសម្រុះសម្រួលរបស់សហភាពអាហ្វ្រិកនិងសង្គមស៊ីវិលកុងហ្គោ; **យើងលើកទឹកចិត្ត** ឱ្យអង្គការអន្តរជាតិហ្វ្រង់កូហ្វូនីបន្តផ្តល់ការគាំទ្រដល់គំនិតផ្តួចផ្តើមសន្តិភាពកម្រិតតំបន់;

ហ្គាបុង

25. **យើងស្វាគមន៍** ចំពោះការត្រឡប់មកវិញនូវសណ្តាប់ធ្នាប់ធម្មនុញ្ញ និងកិច្ចខិតខំប្រឹងប្រែងរបស់អង្គការអន្តរជាតិហ្វ្រង់កូហ្វូនី ដែលបានចូលរួមគាំទ្រដំណើរការអន្តរកាលនេះ ;

26. **យើងលើកទឹកចិត្ត** ឱ្យអាជ្ញាធរបន្តជំរុញកំណែទម្រង់ដែលបានឯកភាព ដើម្បីពង្រឹងសមិទ្ធផលប្រជាធិបតេយ្យ ពង្រឹងនីតិរដ្ឋ ការចូលរួមរបស់ប្រជាពលរដ្ឋ និងអភិបាលកិច្ចល្អ ;

27. **យើងស្វាគមន៍** ប្រទេសហ្គាបុងដែលទទួលបានសមាជិកភាពជាថ្មីឡើងវិញ នៅក្នុងសហភាពអាហ្វ្រិក និងនៅក្នុងសហគមន៍សេដ្ឋកិច្ចនៃរដ្ឋអាហ្វ្រិកកណ្តាល ព្រមទាំងនៅក្នុងបណ្តាប្រទេសក្នុងសហគមន៍ខំមិនវែល ;

ហ៊្សកហ៊្ស៊ី

28. **យើងយកចិត្តទុកដាក់ខ្ពស់** ចំពោះការគោរពគោលការណ៍នីតិរដ្ឋ និងសេរីភាពជាមូលដ្ឋាន ជាពិសេសសេរីភាពសាធារណៈនិងនយោបាយ សេរីភាពនៃការប្រមូលផ្តុំដោយសន្តិវិធីនិងសេរីភាពសារព័ត៌មាន ;

29. **យើងលើកទឹកចិត្ត** ឱ្យបន្តកិច្ចសន្ទនាប្រកបដោយបរិយាបន្ន និងការគោរពស្ថាប័នប្រជាធិបតេយ្យ និងកាតព្វកិច្ចអន្តរជាតិរបស់ហ្សកហ្ស៊ី ;

30. **យើងសម្តែងការព្រួយបារម្ភរបស់យើង** ចំពោះការកាន់កាប់ទឹកដី និងភាពតានតឹងដែលនៅតែបន្តកើតមាននៅក្នុងតំបន់ Tskhinvali/Ossétie ខាងត្បូង និងតំបន់ Abkhazie ; **យើងសោកស្តាយ** ចំពោះទុក្ខវេទនារបស់ប្រជាជនហ្សកហ្ស៊ីដែលត្រូវបានផ្លាស់ទីលំនៅដោយបង្ខំ ; **យើងបញ្ជាក់ជាថ្មី** នូវការគាំទ្ររបស់យើងចំពោះអធិបតេយ្យភាព និងបូរណភាពដែនដីរបស់ប្រទេសហ្សកហ្ស៊ី ;

ហ្គីណេ

31. **យើងស្វាគមន៍** ចំពោះការវិលត្រឡប់ទៅរកសណ្តាប់ធ្នាប់ធម្មនុញ្ញឡើងវិញ ; **យើងកោតសរសើរ** អង្គការអន្តរជាតិហ្វ្រង់កូហ្វូនី ចំពោះការចូលរួមគាំទ្រដល់ដំណើរការអន្តរកាលនេះ និងលើកទឹកចិត្តឱ្យអង្គការអន្តរជាតិហ្វ្រង់កូហ្វូនី បន្តការគាំទ្របន្តទៀត ;

32. **យើងគូសបញ្ជាក់** អំពីសារៈសំខាន់នៃការពង្រឹងសមិទ្ធផលប្រជាធិបតេយ្យ និងការធានាឱ្យស្ថាប័ននីតិរដ្ឋដំណើរការដោយប្រក្រតី ; **យើងលើកទឹកចិត្ត** ឱ្យបង្កើតស្ថាប័ននានាដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ ហើយ**យើងស្នើសុំ**អាជ្ញាធរហ្គីណេឱ្យបន្តកិច្ចខិតខំប្រឹងប្រែង ដើម្បីធានានិងលើកកម្ពស់ការគោរពសិទ្ធិជាមូលដ្ឋាននិងសេរីភាពសាធារណៈ ;

33. **យើងស្វាគមន៍** ចំពោះការទទួលបានសមាជិកភាពឡើងវិញរបស់ប្រទេសហ្គាបុង នៅក្នុងសហភាពអាហ្វ្រិក (UA) និងនៅក្នុងសហគមន៍សេដ្ឋកិច្ចនៃបណ្តារដ្ឋអាហ្វ្រិកខាងលិច;

ហ្គីណេ-ប៊ីស្សូ

34. **យើងសោកស្តាយ** ចំពោះការរំខានដែលនាំទៅដល់ការខកខានដំណើរការបោះឆ្នោតនៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២៥ និងការដួលរលំនៃសណ្តាប់ធ្នាប់ធម្មនុញ្ញដែលបានកើតឡើងជាបន្តបន្ទាប់ ;

35. **យើងបញ្ជាក់ជាថ្មី** នូវការប្តេជ្ញាចិត្តរបស់យើងក្នុងការពង្រឹងលទ្ធិប្រជាធិបតេយ្យ អភិបាលកិច្ចល្អ និងសន្តិភាព; ហើយ**យើងអំពាវនាវ** ឱ្យមានការវិលត្រឡប់យ៉ាងឆាប់រហ័សទៅរកសណ្តាប់ធ្នាប់ធម្មនុញ្ញឡើងវិញ ;

36. **យើងអំពាវនាវ** ឱ្យអនុវត្តឱ្យបានពេញលេញនូវផែនទីបង្ហាញផ្លូវសម្រាប់ដំណើរការអន្តរកាល ដែលត្រូវបានអនុម័ត កាលពីថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២៥ ; **យើងលើកទឹកចិត្ត** ឱ្យអាជ្ញាធរនៃរដ្ឋាភិបាលបណ្តោះអាសន្នបង្កើតលក្ខខណ្ឌចាំបាច់ ដើម្បីរៀបចំការបោះឆ្នោតប្រកបដោយបរិយាបន្ននិងប្រជាធិបតេយ្យ ស្របតាមកាលបរិច្ឆេទដែលបានប្រកាស ;

37. **យើងលើកទឹកចិត្ត** ឱ្យដោះលែងសមាជិកក្រុមប្រឆាំង ; **យើងស្វាគមន៍** ការរៀបចំប្រជាមតិដើម្បីធ្វើវិសោធនកម្មលើរដ្ឋធម្មនុញ្ញ ; ទន្ទឹមនឹងនេះ **យើងគូសបញ្ជាក់** អំពីសារៈសំខាន់នៃការបន្តកិច្ចសន្ទនាជាតិដែលមានការចូលរួមពីគ្រប់ភាគី ដើម្បីឆ្ពោះទៅរកការវិលត្រឡប់យ៉ាងឆាប់រហ័សទៅរកសណ្តាប់ធ្នាប់ធម្មនុញ្ញវិញ ;

ហៃទី

38. **យើងនៅតែព្រួយបារម្ភ** ចំពោះវិបត្តិពហុវិស័យដែលនៅតែបន្តកើតមាន ហើយ**យើងសោកស្តាយ** ចំពោះទុក្ខវេទនារបស់ប្រជាជនហៃទីជាពិសេសប្រជាជនដែលត្រូវបានបង្ខំឱ្យផ្លាស់ទីលំនៅ ; **យើងថ្កោលទោស** អំពើហិង្សាដ៏ធ្ងន់ធ្ងរ និងការរំលោភសិទ្ធិមនុស្សជាបន្តបន្ទាប់ ដែលប្រព្រឹត្តដោយក្រុមទុច្ចរិតប្រដាប់អាវុធ ; **យើងក៏ថ្កោលទោសផងដែរ** ចំពោះរាល់ការគាំទ្រពីមជ្ឈដ្ឋានខាងក្នុងនិងខាងក្រៅប្រទេស ដល់សកម្មភាពរបស់ក្រុមទាំងនេះ ព្រមទាំងថ្កោលទោសចំពោះរាល់សកម្មភាពដែលបង្កអស្ថិរភាពឬរំលោភលើអធិបតេយ្យភាព និងបូរណភាពទឹកដីរបស់ប្រទេសហៃទី ;

39. **យើងទទួលដឹងឮ** អំពីការបញ្ចប់អាណត្តិរបស់ក្រុមប្រឹក្សាប្រធានាធិបតីអន្តរកាល និងការផ្ទេរតំណែងដឹកនាំអំណាចនីតិប្រតិបត្តិហៃទី ទៅ ឯកឧត្តម Alix Didier FILS-AIME ជានាយករដ្ឋមន្ត្រី កាលពីថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០២៦ កន្លងទៅនេះ; **យើងស្វាគមន៍** កិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាលក្នុងការស្តារសន្តិសុខឡើងវិញ ដែលជាលក្ខខណ្ឌចាំបាច់សម្រាប់ការរៀបចំការបោះឆ្នោត ដើម្បីឱ្យប្រជាជនអាចជ្រើសរើសតំណាងស្របច្បាប់របស់ខ្លួន ហើយយើងក៏ស្វាគមន៍ផងដែរចំពោះការអនុម័តដោយក្រុមប្រឹក្សាគណៈរដ្ឋមន្ត្រី នូវអនុក្រឹត្យស្តីពីការបោះឆ្នោត និងការរៀបចំថវិកាសម្រាប់ការបោះឆ្នោតសកល;

40. **យើងលើកទឹកចិត្ត** ឱ្យរដ្ឋាភិបាល តួអង្គនយោបាយ និងសង្គមស៊ីវិលបន្តកិច្ចសន្ទនា និងរួមគ្នាបង្កើតលក្ខខណ្ឌចាំបាច់សម្រាប់ដំណើរការអន្តរកាល ដែលផ្តោតលើអភិបាលកិច្ចតាមបែបប្រជាធិបតេយ្យ ការពង្រឹងសន្តិសុខនិងការរៀបចំការបោះឆ្នោតដោយសេរី គួរឱ្យទុកចិត្ត មានតម្លាភាព និងមានការចូលរួមពីគ្រប់ភាគី ;

41. **យើងស្វាគមន៍** ចំពោះគំនិតផ្តួចផ្តើមផ្នែកការទូតរបស់**អគ្គលេខាធិការ** និងកិច្ចខិតខំប្រឹងប្រែងរបស់ឯកឧត្តម Domitien NDAYIZEYE បេសកជនពិសេសទទួលបន្ទុកតាមដានស្ថានការណ៍នៅប្រទេសហៃទី ក្នុងការបំពេញបេសកកម្មស្វែងរកព័ត៌មាននិងទំនាក់ទំនង នៅទីក្រុងព័រអូប្រាំង ;

42. **យើងស្វាគមន៍** កិច្ចខិតខំប្រឹងប្រែងរបស់នគរបាលជាតិហៃទី និងកងកម្លាំងប្រដាប់អាវុធហៃទី (FAD'H) ដោយមានការគាំទ្រពី**បេសកកម្មពហុជាតិគាំទ្រសន្តិសុខ** (MMAS) ដឹកនាំដោយប្រទេសកេនយ៉ា នៅឆ្នាំ២០២៤ និងឆ្នាំ២០២៥ ; **យើងសូមគោរពវិញ្ញាណក្ខន្ធ** របស់សមាជិកនៃបេសកកម្មនេះ ដែលបានពលីជីវិតក្នុងពេលបំពេញភារកិច្ច ; យើងទទួលស្គាល់ការបញ្ចប់អាណត្តិ និងលទ្ធផលការងារនៃបេសកកម្មខាងលើ; **យើងគាំទ្រ** ការដាក់ពង្រាយកងកម្លាំងបង្ក្រាបក្រុមទុច្ចរិត ដើម្បីបន្តវេនពីបេសកកម្មពហុជាតិគាំទ្រសន្តិសុខ ហើយ **យើងស្វាគមន៍** ចំពោះការប្តេជ្ញាចិត្តរបស់ប្រទេសនានាដែលបានចូលរួមចំណែក ជាពិសេសបណ្តាប្រទេសនិយាយភាសាបារាំងដែលបានបញ្ជូនកងកម្លាំងតាមជំនាញ; **យើងស្វាគមន៍** ចំពោះសេចក្តីសម្រេចលេខ XXXX (២០២៦) របស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ដែលសម្រេចពន្យារអាណត្តិរបស់កងកម្លាំងបង្ក្រាបក្រុមទុច្ចរិត (FRG) សម្រាប់រយៈពេល [មួយឆ្នាំ] បន្ថែមទៀត;

43. **យើងអំពាវនាវ** ដល់សហគមន៍អន្តរជាតិឱ្យផ្តល់ការគាំទ្រដល់កងនគរបាលជាតិហៃទី កងកម្លាំងប្រដាប់អាវុធហៃទី និងកងកម្លាំងបង្ក្រាបក្រុមទុច្ចរិត ;**យើងកោតសរសើរ** គំនិតផ្តួចផ្តើមរបស់អង្គការអន្តរជាតិហ្វ្រង់កូហ្វូនីក្នុងការផ្តល់ការបណ្តុះបណ្តាលផ្នែកបច្ចេកទេស ភាសា និងអន្តរវប្បធម៌ ដល់បុគ្គលិកមកពីបណ្តាប្រទេសដែលចូលរួមចំណែកក្នុងបេសកកម្មពហុជាតិគាំទ្រសន្តិសុខ និងក្នុងកងកម្លាំងបង្ក្រាបក្រុមទុច្ចរិត ព្រមទាំងការពង្រឹងសមត្ថភាពរបស់កងនគរបាលជាតិហៃទី និងកងកម្លាំងប្រដាប់អាវុធហៃទី ;

44. **យើងលើកទឹកចិត្ត** ឱ្យអង្គការអន្តរជាតិហ្វ្រង់កូហ្វូនី បន្តនិងពង្រីកសកម្មភាពរបស់ខ្លួនក្នុងការគាំទ្រការស្តារសន្តិសុខឡើងវិញ ការរៀបចំការបោះឆ្នោត និងការពង្រឹងអភិបាលកិច្ចប្រជាធិបតេយ្យ ;

លីបង់

45. **យើងថ្កោលទោស** ចំពោះការវាយប្រហារតាមអាកាសដែលបានបណ្តាលឱ្យប្រជាជនស៊ីវិលបាត់បង់ជីវិតយ៉ាងច្រើន ការបង្ខំឱ្យប្រជាជនផ្លាស់ទីលំនៅ និងបំផ្លិចបំផ្លាញហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗ និងសម្បត្តិវប្បធម៌ ព្រមទាំងថ្កោលទោសចំពោះការវាយប្រហារទៅលើកងកម្លាំងប្រដាប់អាវុធលីបង់ កងកម្លាំងបណ្តោះអាសន្នរបស់អង្គការសហប្រជាជាតិប្រចាំប្រទេសលីបង់និងប្រជាជនស៊ីវិល ; **យើងអំពាវនាវ**ឱ្យបញ្ឈប់ការវាយប្រហារទាំងនេះជាបន្ទាន់ និងគោរពច្បាប់មនុស្សធម៌អន្តរជាតិ ;

46. **យើងស្វាគមន៍** កិច្ចចរចាដែលកំពុងបន្ត រវាងលីបង់ និងអ៊ីស្រាអែល ហើយ**យើងអំពាវនាវ** ឱ្យគ្រប់ភាគីធានាឱ្យបាននូវការអនុវត្តបទឈប់បាញ់ប្រកបដោយប្រសិទ្ធភាព និងការប្តេជ្ញាចិត្តដែលមានចែងក្នុងកិច្ចព្រមព្រៀងក្របខ័ណ្ឌត្រីភាគី ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២៦; **យើងស្វាគមន៍** កិច្ចខិតខំប្រឹងប្រែងរបស់សហគមន៍អន្តរជាតិ ជាពិសេសបណ្តារដ្ឋនិងរដ្ឋាភិបាលសមាជិកហ្វ្រង់កូហ្វូនី ក្នុងការស្វែងរកដំណោះស្រាយប្រកបដោយចីរភាពចំពោះជម្លោះនេះ ហើយ**យើងបញ្ជាក់ជាថ្មី** នូវការប្តេជ្ញាចិត្តរបស់យើងក្នុងការគោរពអធិបតេយ្យភាព និងបូរណភាពទឹកដីរបស់ប្រទេសលីបង់;

47. **យើងសូមសាទរ** ចំពោះការបោះឆ្នោតជ្រើសតាំងប្រធានាធិបតី កាលពីខែមករា ឆ្នាំ២០២៥ និងការបង្កើតរដ្ឋាភិបាល នៅខែកុម្ភៈ ឆ្នាំ២០២៥ ; **យើងស្វាគមន៍ និងលើកទឹកចិត្ត** កិច្ចខិតខំប្រឹងប្រែងរបស់អាជ្ញាធរលីបង់ ក្នុងការអនុវត្តកំណែទម្រង់ចាំបាច់ និងសេចក្តីសម្រេចនានារបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ជាពិសេសពាក់ព័ន្ធនឹងការរំសាយអាវុធរបស់ក្រុមជីវពលប្រដាប់អាវុធមិនមែនរដ្ឋ ; ក្នុងន័យនេះ **យើងគាំទ្រ** តួនាទីរបស់កងកម្លាំងប្រដាប់អាវុធលីបង់ ក្នុងការធានាអធិបតេយ្យនិងឯកភាពជាតិ ; **យើងអំពាវនាវ** ឱ្យរដ្ឋនិងរដ្ឋាភិបាលហ្វ្រង់កូហ្វូនី បន្តនិងបង្កើនការគាំទ្រផ្នែកនយោបាយ បច្ចេកទេស និងហិរញ្ញវត្ថុ ក្នុងស្មារតីសាមគ្គីភាពដល់ស្តាប់ននានារបស់លីបង់ និងដល់ការស្តារសេដ្ឋកិច្ចនិងសង្គម ដែលជាលក្ខខណ្ឌចាំបាច់សម្រាប់ការធានាស្ថិរភាពនៅប្រទេសលីបង់និងនៅក្នុងតំបន់ទាំងមូល;

ម៉ាដាហ្គាស្កា

48. **យើងទទួលដឹងឮ** សេចក្តីសម្រេចរបស់តុលាការធម្មនុញ្ញជាន់ខ្ពស់ ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២៥ ដែលបានប្រកាសថា តំណែងប្រធានាធិបតី និងប្រធានព្រឹទ្ធសភា គឺនៅទំនេរ ហើយបានប្រគល់ភារកិច្ចជូនអាជ្ញាធរយោធា ដឹកនាំដោយវរសេនីយ៍ឯក Michaël Randrianirina ឱ្យបំពេញតួនាទីជាប្រមុខរដ្ឋ ;

49. **យើងទទួលដឹងឮ** ដំណើរការរៀបចំរដ្ឋឡើងវិញដោយអាជ្ញាធរថ្មី (Refondation) ព្រមទាំងទទួលដឹងឮអំពីតារាងកំណត់កាលបរិច្ឆេទដែលបានបញ្ជូនទៅសហគមន៍អភិវឌ្ឍន៍អាហ្វ្រិកខាងត្បូង កាលពីថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៦ ដែលកំណត់ឱ្យដំណើរការនេះបញ្ចប់ត្រឹមចុងឆ្នាំ២០២៧ ;

50. **យើងស្វាគមន៍** ការចាប់ផ្តើមដំណើរការពិគ្រោះយោបល់ថ្នាក់ជាតិ ហើយ**យើងរំឭក** អំពីការប្តេជ្ញាចិត្តរបស់យើងក្នុងការធានាឱ្យដំណើរការនេះមានការចូលរួមពីគ្រប់ភាគី ដើម្បីធ្វើឱ្យបរិយាកាសវិលមករកភាពស្ងប់ស្ងាត់ឡើងវិញ និងបង្កើតលក្ខខណ្ឌអំណោយផលសម្រាប់កិច្ចសន្ទនាប្រកបដោយការស្ថាបនា និងឆ្លើយតបទៅនឹងសេចក្តីប្រាថ្នារបស់ប្រជាពលរដ្ឋ ជាពិសេសយុវជន ពាក់ព័ន្ធនឹងអភិបាលកិច្ច ការទទួលបានសេវាសាធារណៈ និងកំណែទម្រង់សេដ្ឋកិច្ច-សង្គម ;

51. **យើងអំពាវនាវ** ឱ្យគោរពសិទ្ធិនិងសេរីភាពជាមូលដ្ឋាន ហើយ**យើងនៅតែព្រួយបារម្ភ** ចំពោះសេចក្តីរាយការណ៍ថាមានការចាប់ខ្លួននិងភាពតានតឹងផ្នែកសន្តិសុខ ; **យើងអំពាវនាវយ៉ាងទទូច** ឱ្យបង្កើតបរិយាកាសនយោបាយប្រកបដោយសន្តិភាព ដើម្បីធានាផលប្រយោជន៍របស់ប្រជាជន ;

52. **យើងអំពាវនាវយ៉ាងទទូច** ដល់**អាជ្ញាធរថ្មីសម្រាប់ការរៀបចំប្រទេសឡើងវិញ** (Refondation) ឱ្យខិតខំប្រឹងប្រែងឱ្យអស់ពីលទ្ធភាព ដើម្បីបង្កើតលក្ខខណ្ឌសម្រាប់ការវិលត្រឡប់ទៅរកសណ្តាប់ធ្នាប់ធម្មនុញ្ញនិងបែបប្រជាធិបតេយ្យឱ្យបានឆាប់បំផុត ជាពិសេសតាមរយៈការអនុវត្តកំណែទម្រង់រដ្ឋធម្មនុញ្ញ និងកំណែទម្រង់ការបោះឆ្នោត តាមកាលបរិច្ឆេទកំណត់ដែលបានប្រកាស ក៏ដូចជាការរៀបចំការបោះឆ្នោតមួយដែលគួរឱ្យទុកចិត្តមានតម្លាភាព និងមានការចូលរួមពីគ្រប់ភាគី ស្របតាមបទដ្ឋានអន្តរជាតិនិងតំបន់ ;

53. ក្នុង**ន័យនេះ** **យើងគាំទ្រ** កិច្ចខិតខំប្រឹងប្រែងរបស់អង្គការអន្តរជាតិហ្វ្រង់កូហ្វូនី ដោយសហការជាមួយសហគមន៍អភិវឌ្ឍន៍អាហ្វ្រិកខាងត្បូង សហភាពអាហ្វ្រិក អង្គការសហប្រជាជាតិ ព្រមទាំងដៃគូបច្ចេកទេស និងហិរញ្ញវត្ថុដទៃទៀត ;

54. **យើងស្នើឱ្យ**អង្គការអន្តរជាតិហ្វ្រង់កូហ្វូនី បន្តគាំទ្រដំណើរការរៀបចំប្រទេសឡើងវិញ តាមរយៈការគាំទ្រដល់ស្ថាប័ននិងតួអង្គពាក់ព័ន្ធ ដែលចូលរួមក្នុងការពង្រឹងលទ្ធិប្រជាធិបតេយ្យ សន្តិភាព និងនីតិរដ្ឋ ;

ម៉ូលដាវី

55. **យើងបញ្ជាក់អះអាងជាថ្មី** នូវការគាំទ្ររបស់យើងចំពោះអធិបតេយ្យភាព និងបូរណភាពទឹកដីរបស់សាធារណរដ្ឋម៉ូលដាវី ដែលស្ថិតនៅក្នុងខ្សែបន្ទាត់ព្រំដែនទទួលស្គាល់ជាអន្តរជាតិ; **យើងបញ្ជាក់អះអាងជាថ្មី** ថា វត្តមានកងកម្លាំងយោធារុស្ស៊ីនៅលើទឹកដីនៃសាធារណរដ្ឋម៉ូលដាវី ដោយគ្មានការយល់ព្រមពីប្រទេសនេះ គឺជាការរំលោភលើអធិបតេយ្យភាព បូរណភាពទឹកដី និងអព្យាក្រឹតភាពដែលមានចែងក្នុងរដ្ឋធម្មនុញ្ញរបស់ម៉ូលដាវី; **យើងទាមទារ** ឱ្យដកកងកម្លាំង និងសម្ភារៈយោធាទាំងអស់របស់សហព័ន្ធរុស្ស៊ី ដែលកំពុងឈរជើងដោយខុសច្បាប់នៅតំបន់Transnistrie នៃសាធារណរដ្ឋម៉ូលដាវី ឱ្យបានទាំងស្រុងនិងដោយគ្មានលក្ខខណ្ឌ; **យើងថ្កោលទោស** ការរំលោភដែនអាកាសរបស់សាធារណរដ្ឋម៉ូលដាវីជាបន្តបន្ទាប់ ដោយយានជ្រូនឬមីស៊ីលរបស់រុស្ស៊ី ក្នុងក្របខ័ណ្ឌនៃសង្គ្រាមឈ្លានពានរបស់សហព័ន្ធរុស្ស៊ីមកលើអ៊ុយក្រែន;

56. **យើងគាំទ្រ**កំណែទម្រង់បែបប្រជាធិបតេយ្យដែលកំពុងដំណើរការនៅសាធារណរដ្ឋម៉ូលដាវី ជាពិសេសការពង្រឹងសមត្ថភាពស្ថាប័ន ក្នុងក្របខ័ណ្ឌនៃដំណើរការចូលជាសមាជិកសហភាពអឺរ៉ុបរបស់ប្រទេសនេះ; **យើងស្វាគមន៍** កិច្ចខិតខំប្រឹងប្រែងរបស់ស្ថាប័ននានានៅម៉ូលដាវី ក្នុងការការពារភាពត្រឹមត្រូវនៃដំណើរការបោះឆ្នោត ទោះបីជាមានការជ្រៀតជ្រែកពីសំណាក់រុស្ស៊ី និងការគំរាមកំហែងគ្រប់បែបយ៉ាងដែលបានកើតឡើងក្នុងអំឡុងពេលនៃការបោះឆ្នោតជ្រើសរើសប្រធានាធិបតីនិងការធ្វើប្រជាមតិធ្វើវិសោធនកម្មលើរដ្ឋធម្មនុញ្ញកាលពីខែតុលា ឆ្នាំ២០២៤ ក៏ដូចជាការបោះឆ្នោតជ្រើសរើសសមាជិកសភា នៅថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ ២០២៥ ក៏ដោយ; **យើងបញ្ជាក់ជាថ្មី** នូវការប្តេជ្ញាចិត្តរបស់យើងក្នុងការគាំទ្រសាធារណរដ្ឋម៉ូលដាវី ក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីពង្រឹងភាពធន់និងសមត្ថភាពរបស់ខ្លួន ក្នុងការទប់ទល់នឹងការគំរាមកំហែងបង្កអស្ថិរភាពផ្សេងៗទៀតដោយប្រទេសរុស្ស៊ី;

57. **យើងស្វាគមន៍**ការគាំទ្រ**របស់**អង្គការអន្តរជាតិហ្វ្រង់កូហ្វូនី ក្នុងការពង្រឹងនីតិរដ្ឋ ការប្រយុទ្ធប្រឆាំងនឹងព័ត៌មានក្លែងក្លាយនិងការគាំទ្រសង្គមស៊ីវិល ហើយ**យើងលើកទឹកចិត្ត** ឱ្យបន្តអនុវត្តអនុសាសន៍នានាដែលបានលើកឡើងដោយបេសកកម្មសង្កេតការណ៍បោះឆ្នោតរបស់ហ្វ្រង់កូហ្វូនី ;

<u>ម៉ូសំប៊ិក</u>

58. **យើងសោកស្តាយ** ចំពោះការបន្តធ្លាក់ចុះនូវស្ថានភាពសន្តិសុខ និងមនុស្សធម៌នៅខេត្តកាបូ ដេលហ្គាដូ (Cabo Delgado) ;

59. **យើងថ្កោលទោស** ការវាយប្រហារកេរវៃកម្ម និងអំពើរំលោភបំពាននានាលើប្រជាជនស៊ីវិល ហើយ**យើងអំពាវនាវ** ឱ្យគ្រប់ភាគីពាក់ព័ន្ធទាំងអស់គោរពសិទ្ធិមនុស្ស និងច្បាប់មនុស្សធម៌អន្តរជាតិ ;

60. **យើងស្វាគមន៍** កិច្ចខិតខំប្រឹងប្រែងរបស់អាជ្ញាធរ ដោយមានការគាំទ្រពីប្រទេសជាដៃគូទ្វេភាគី កម្រិតតំបន់ និងអន្តរជាតិ ; **យើងសូមគោរពវិញ្ញាណក្ខន្ធ** យោធិនដែលបានពលីជីវិតក្នុងពេលបំពេញបេសកកម្ម ; **យើងគាំទ្រ** ការបន្តគំនិតផ្តួចផ្តើមនានា ដើម្បីពង្រឹងកិច្ចការពារប្រជាជនស៊ីវិល និងស្តារសន្តិសុខនិងស្ថិរភាពប្រកបដោយចីរភាពនៅក្នុងតំបន់ដែលរងផលប៉ះពាល់ ដើម្បីសំដៅបង្កើតបរិយាកាសអំណោយផលដល់កិច្ចសន្ទនានិងសន្តិភាពយូរអង្វែង ;

<u>ឆាដ</u>

61. **យើងសម្តែងនូវក្តីព្រួយបារម្ភ** ចំពោះផលប៉ះពាល់នៃវិបត្តិនៅស៊ូដង់ និងលីប៊ី ដែលបង្កផលវិបាកដល់ស្ថានភាពសន្តិសុខនិងមនុស្សធម៌នៅប្រទេសឆាដ ជាពិសេសនៅតាមតំបន់ព្រំដែន ;

62. យើង**លើកទឹកចិត្ត** ដល់កិច្ចខិតខំប្រឹងប្រែងរបស់អាជ្ញាធរនិងដៃគូក្នុងតំបន់ ដើម្បីរក្សាស្ថិរភាពនៅប្រទេសឆាដ ពង្រឹងសន្តិសុខនិងការឆ្លើយតបផ្នែកមនុស្សធម៌នៅតាមតំបន់ព្រំដែន ព្រមទាំងទប់ស្កាត់ការកើនឡើងនៃភាពតានតឹង;

<u>អ៊ុយក្រែន</u>

63. **យើងបញ្ជាក់ជាថ្មី** នូវការប្តេជ្ញាចិត្តរបស់យើងក្នុងការគាំទ្រអធិបតេយ្យភាព ឯករាជ្យភាព ឯកភាព និងបូរណភាពទឹកដីរបស់អ៊ុយក្រែន ដែលស្ថិតនៅក្នុងខ្សែព្រំដែនទទួលស្គាល់ជាអន្តរជាតិ រួមទាំងដែនទឹករបស់អ៊ុយក្រែន ដែលកំពុងប្រឈមនឹងការឈ្លានពានផ្នែកយោធាពីសហព័ន្ធរុស្ស៊ីលើប្រទេសអ៊ុយក្រែន ហើយ**យើងទាមទារ** ឱ្យមានបទឈប់បាញ់ជាបន្ទាន់ យ៉ាងពេញលេញ និងដោយគ្មានលក្ខខណ្ឌ ;

64. **យើងគាំទ្រ** រាល់គំនិតផ្តួចផ្តើមឱ្យមានកិច្ចសន្ទនានិងការសម្រុះសម្រួល ដែលមានគោលបំណងជំរុញការដោះស្រាយជម្លោះដោយសន្តិវិធី ; ក្នុងន័យនេះ **យើងស្វាគមន៍** កិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋ និងរដ្ឋាភិបាលសមាជិកហ្វ្រង់កូហ្វូនីមួយចំនួនធំ ដែលបានចូលរួមក្នុងដំណើរការចរចាឆ្ពោះទៅរកសន្តិភាពដ៏យុត្តិធម៌និងយូរអង្វែង ស្របតាមច្បាប់អន្តរជាតិ និងគោលការណ៍នៃធម្មនុញ្ញអង្គការសហប្រជាជាតិ ;

65. **យើងអំពាវនាវ** ឱ្យមានការគោរពច្បាប់មនុស្សធម៌អន្តរជាតិ ដែលការរំលោភបំពានធ្ងន់ធ្ងរបំផុតលើច្បាប់នេះ អាចចាត់ទុកជាឧក្រិដ្ឋកម្មសង្គ្រាម ;

66. **យើងថ្កោលទោស** ការបន្តនិងការបង្កើនការវាយប្រហាររបស់សហព័ន្ធរុស្ស៊ី មកលើប្រជាជននិងទ្រព្យសម្បត្តិស៊ីវិល ហេដ្ឋារចនាសម្ព័ន្ធថាមពលសំខាន់ៗ និងហេដ្ឋារចនាសម្ព័ន្ធកំពង់ផែ ; **យើងមិនអាចទទួលយកបាន** នូវស្ថានភាពមនុស្សធម៌ដែលកំពុងធ្លាក់ចុះដ៏ធ្ងន់ធ្ងរ ជាពិសេសនៅពេលដែលរដូវរងាខិតជិតមកដល់ ;

67. **យើងថ្កោលទោស** វិធីសាស្ត្របំភាន់និងបង្ខិតបង្ខំរបស់សហព័ន្ធរុស្ស៊ី ក្នុងការជ្រើសរើសយុទ្ធជនបរទេសឱ្យចូលរួមក្នុងសង្គ្រាមនេះ ហើយ**យើងអំពាវនាវ** ឱ្យពង្រឹងមធ្យោបាយចាំបាច់នានា ដើម្បីទប់ស្កាត់ការប្រើប្រាស់យុវជនជាឧបករណ៍ ជាពិសេសតាមរយៈថ្នាលឌីជីថល ;

68. **យើងទាមទារ** ឱ្យមានការដោះដូរឈ្លើយសឹកទាំងអស់ ការដោះលែងជនគ្រប់រូបដែលត្រូវបានឃុំខ្លួនដោយខុសច្បាប់ និងការបញ្ជូនត្រឡប់មកវិញនូវជនស៊ីវិលដែលត្រូវបានផ្ទេរឬនិរទេសដោយបង្ខំ ដោយរួមទាំងកុមារផងដែរ ;

ដោយចាត់ទុក ការរួមចំណែករបស់ហ្វ្រង់កូហ្វូនី ចំពោះសន្តិភាព ស្ថិរភាព និងសន្តិសុខសកល ជាចំណុចស្នូលនៃកង្វល់របស់យើង និង**ដោយពិចារណា**ពីផលប៉ះពាល់ដោយផ្ទាល់នៃវិបត្តិក្នុងតំបន់មួយចំនួនមកលើលំហហ្វ្រង់កូហ្វូនី; **យើងសម្រេចចិត្ត**បន្តកិច្ចខិតខំប្រឹងប្រែងរបស់យើងក្នុងស្ថានភាពផ្សេងទៀតដូចខាងក្រោម៖

សមុទ្រចិនខាងត្បូង

69. **យើងកត់សម្គាល់**នូវក្តីព្រួយបារម្ភដែលលើកឡើងដោយរដ្ឋមួយចំនួន ចំពោះការវិវត្តថ្មីៗនៅសមុទ្រចិនខាងត្បូង ព្រមទាំងសេចក្តីថ្លែងការណ៍រួមនៃកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ានលើកទី៥៩ ដែលបានប្រព្រឹត្តទៅនៅទីក្រុងម៉ានីល ប្រទេសហ្វីលីពីន ក្នុងខែកក្កដា ឆ្នាំ២០២៦ ; **យើងអំពាវនាវជាថ្មី** ឱ្យភាគីពាក់ព័ន្ធរក្សាទំនុកចិត្តទៅវិញទៅមក និងចៀសវាងរាល់សកម្មភាពដែលអាចបង្កឱ្យមានភាពតានតឹងកើនឡើង;

70. **យើងអំពាវនាវ** ឱ្យដោះស្រាយវិវាទទាំងឡាយដោយសន្តិវិធី ស្របតាមច្បាប់អន្តរជាតិ ជាពិសេសអនុសញ្ញាអង្គការសហប្រជាជាតិឆ្នាំ១៩៨២ ស្តីពីច្បាប់សមុទ្រ (UNCLOS) ; **យើងបញ្ជាក់ជាថ្មី** ពីសារៈសំខាន់នៃការធានាសន្តិភាព សន្តិសុខ និងស្ថិរភាព ព្រមទាំងសេរីភាពនៃការធ្វើនាវាចរណ៍ និងការហោះហើរលើសមុទ្រនេះ ; ក្នុងន័យនេះ **យើងស្វាគមន៍** កិច្ចខិតខំប្រឹងប្រែងនានា ដើម្បីធានាការអនុវត្តឱ្យបានពេញលេញនូវសេចក្តីប្រកាសស្តីពីក្រមប្រតិបត្តិរបស់គ្រប់ភាគីនៅសមុទ្រចិនខាងត្បូង (DOC) ; **យើងអបអរសាទរ** ចំពោះវឌ្ឍនភាពដ៏សំខាន់ដែលសម្រេចបានក្នុងកិច្ចចរចាដើម្បីបង្កើតក្រមប្រតិបត្តិ (COC) ដែលមានប្រសិទ្ធភាព មានខ្លឹមសារជាក់ស្តែងនិងស្របតាមច្បាប់អន្តរជាតិ ជាពិសេសអនុសញ្ញាអង្គការសហប្រជាជាតិឆ្នាំ១៩៨២ ស្តីពីច្បាប់សមុទ្រ (UNCLOS) ហើយ**យើងអំពាវនាវ** ឱ្យបន្តកិច្ចខិតខំប្រឹងប្រែង ដើម្បីបញ្ចប់កិច្ចចរចាលើក្រមប្រតិបត្តិនេះឱ្យបានឆាប់បំផុត;

តំបន់មជ្ឈិមបូព៌ា

71. **យើងអំពាវនាវ** ឱ្យគោរពច្បាប់អន្តរជាតិ ជាពិសេសច្បាប់មនុស្សធម៌អន្តរជាតិ ព្រោះការរំលោភបំពានធ្ងន់ធ្ងរបំផុតលើច្បាប់នេះ អាចចាត់ទុកជាឧក្រិដ្ឋកម្មសង្គ្រាម ;

72. **យើងសម្តែងនូវក្តីព្រួយបារម្ភ** ចំពោះផលវិបាកផ្នែកមនុស្សធម៌ សង្គម និងសេដ្ឋកិច្ច ដែលបណ្តាលមកពីជម្លោះក្នុងតំបន់ ព្រមទាំងឧក្រិដ្ឋកម្មសង្គ្រាមនិងការរំលោភបំពានជាច្រើនលើច្បាប់អន្តរជាតិ ជាពិសេសច្បាប់មនុស្សធម៌អន្តរជាតិ ; **យើងថ្កោលទោស** រាល់ការរំលោភបំពានលើច្បាប់អន្តរជាតិ និងច្បាប់មនុស្សធម៌អន្តរជាតិ ជាពិសេសនៅតំបន់ហ្គាហ្សា ព្រមទាំងរាល់ការវាយប្រហារលើប្រជាជនស៊ីវិលនិងហេដ្ឋារចនាសម្ព័ន្ធស៊ីវិល និងរាល់ការញុះញង់ឱ្យមានអំពើហិង្សា ;

73. **យើងបញ្ជាក់ជាថ្មី** នូវការគាំទ្ររបស់យើងចំពោះកិច្ចខិតខំប្រឹងប្រែង ដើម្បីសម្រេចបានសន្តិភាពប្រកបដោយយុត្តិធម៌ ចីរភាព និងគ្រប់ជ្រុងជ្រោយ ស្របតាមច្បាប់អន្តរជាតិ និងធម្មនុញ្ញអង្គការសហប្រជាជាតិ សំដៅបញ្ចប់ការកាន់កាប់របស់អ៊ីស្រាអែល និងដើម្បីទទួលស្គាល់សិទ្ធិស្របច្បាប់របស់ប្រជាជនប៉ាឡេស្ទីនក្នុងការកំណត់ជោគវាសនារបស់ខ្លួនតាមរយៈលទ្ធភាពអនុវត្តដំណោះស្រាយរដ្ឋពីរ និងការបង្កើតរដ្ឋប៉ាឡេស្ទីនមួយដែលមានឯករាជ្យ អធិបតេយ្យភាព អាចដំណើរការបានដោយចីរភាព និងមានទឹកដីជាប់គ្នា ដោយផ្អែកលើព្រំដែនថ្ងៃទី៤ ខែមិថុនា ឆ្នាំ១៩៦៧ សេចក្តីសម្រេចនានារបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ សន្និសីទទីក្រុងម៉ាឌ្រីដឆ្នាំ១៩៩១ និងគំនិតផ្តួចផ្តើមសន្តិភាពដែលបានអនុម័តនៅកិច្ចប្រជុំកំពូលអារ៉ាប់ទីក្រុងបេរូត ឆ្នាំ២០០២ ព្រមទាំងសេចក្តីប្រកាសទីក្រុងញូវយ៉ក ឆ្នាំ២០២៥ ស្តីពីការដោះស្រាយបញ្ហាប៉ាឡេស្ទីនដោយសន្តិវិធីនិងការអនុវត្តដំណោះស្រាយរដ្ឋពីរ;

74. **យើងស្នើឱ្យបញ្ឈប់** ការចាប់ខ្លួននិងការឃុំខ្លួនដោយគ្មានមូលហេតុ ហើយអនុញ្ញាតឱ្យជនភៀសខ្លួនទាំងអស់ជាពិសេសកុមារ ឱ្យត្រឡប់ទៅលំនៅឋានវិញ; **យើងបញ្ជាក់ម្តងទៀត** ពីការបដិសេធចំពោះការផ្លាស់ទីប្រជាជនដោយបង្ខំ និងបដិសេធចោលនូវគ្រប់ការកាន់កាប់និងការបំបែកទឹកដីដែលប្រជាជនប៉ាឡេស្ទីនធ្លាប់រស់នៅ; **យើងថ្កោលទោសផងដែរ** ចំពោះសកម្មភាពពង្រីកការត្រួតត្រា និងចំពោះវិធានការនានាក្នុងបំណងកែប្រែទិដ្ឋភាពផ្លូវច្បាប់ ស្ថានភាពភូមិសាស្ត្រ ឬស្ថានភាពប្រជាសាស្ត្ររបស់ដែនដីនេះ ;

75. **យើងបញ្ជាក់ជាថ្មី** ពីភាពចាំបាច់បន្ទាន់ក្នុងការបង្កើនជំនួយមនុស្សធម៌និងការធានាឱ្យការដឹកជញ្ជូននិងការចែកចាយជំនួយទាំងនោះប្រព្រឹត្តទៅដោយសុវត្ថិភាពនិងគ្មានការរារាំង ព្រមទាំងផ្តល់ការគាំទ្រប្រកបដោយសមធម៌ដល់ទីភ្នាក់ងារសង្គ្រោះនិងការងាររបស់អង្គការសហប្រជាជាតិសម្រាប់ជនភៀសខ្លួនប៉ាឡេស្ទីននៅតំបន់មជ្ឈិមបូព៌ា (UNRWA) ដែលបានរួមចំណែកដល់ស្ថិរភាពក្នុងតំបន់ តាមរយៈការបំពេញបេសកកម្មជួយដល់ជនភៀសខ្លួនប៉ាឡេស្ទីន ;

76. **យើងថ្កោលទោស** ការវាយប្រហារតាមអាកាសដែលតម្រង់គោលដៅលើទឹកដី និងហេដ្ឋារចនាសម្ព័ន្ធស៊ីវិលរបស់រដ្ឋនិងរដ្ឋាភិបាលសមាជិក និងសមាជិកសង្កេតការណ៍នៃអង្គការអន្តរជាតិហ្វ្រង់កូហ្វូនី ;

77. **យើងបញ្ជាក់ជាថ្មី** នូវការគាំទ្ររបស់យើងចំពោះសេរីភាពនៃការធ្វើនាវាចរណ៍ ដូចមានចែងក្នុងអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីច្បាប់សមុទ្រ ហើយ**យើងអំពាវនាវ**ឱ្យបើកច្រកសមុទ្រហ័រមូសឡើងវិញដោយគ្មានការរឹតត្បិតនិងស្របតាមច្បាប់សមុទ្រ ;

78. **យើងស្វាគមន៍ និងលើកទឹកចិត្ត** ដល់កិច្ចខិតខំប្រឹងប្រែងសម្រុះសម្រួល ដឹកនាំដោយប្រទេសប៉ាគីស្ថាន កាតា និងអូម៉ង់ ព្រមទាំងការប្តេជ្ញាចិត្តនិងការចូលរួមយ៉ាងសកម្មរបស់រដ្ឋហ្វ្រង់កូហ្វូនីក្នុងតំបន់ ក្នុងដំណើរការនេះ ; **យើងអំពាវនាវ**ឱ្យអង្គការអន្តរជាតិហ្វ្រង់កូហ្វូនី គាំទ្រដល់កិច្ចខិតខំប្រឹងប្រែងផ្នែកការទូតនិងមនុស្សធម៌ដើម្បីលើកកម្ពស់សន្តិភាពក្នុងតំបន់ ស្របតាមអាណត្តិរបស់ខ្លួន ;

តំបន់សាអែល

79. **យើងសោកស្តាយ** ចំពោះស្ថានភាពសន្តិសុខនិងមនុស្សធម៌នៅក្នុងតំបន់នេះ ដែលនៅតែបន្តធ្លាក់ចុះនិងកាន់តែធ្ងន់ធ្ងរឡើង ដោយសារសកម្មភាពរបស់ក្រុមភេរវកម្ម និងផលប៉ះពាល់ដ៏ខ្លាំងក្លានៃការប្រែប្រួលអាកាសធាតុ ;

80. **យើងសម្តែងនូវក្តីព្រួយបារម្ភ** ចំពោះការរីករាលដាលនៃអសន្តិសុខទៅកាន់បណ្តាប្រទេសជិតខាងនិងតំបន់ឆ្នេរសមុទ្រអាហ្វ្រិកខាងលិច ;

81. **យើងអំពាវនាវ** ឱ្យប្រទេសដែលពាក់ព័ន្ធទាំងអស់ពង្រឹងកិច្ចសហប្រតិបត្តិការនិងកិច្ចសន្ទនារវាងគ្នា ជាពិសេសក្នុងក្របខ័ណ្ឌនៃសហភាពអាហ្វ្រិក សហគមន៍សេដ្ឋកិច្ចនៃរដ្ឋអាហ្វ្រិកខាងលិច និងយន្តការតំបន់ដែលមានសមត្ថកិច្ចពាក់ព័ន្ធផ្សេងទៀត ;

82. **យើងលើកទឹកចិត្ត** អង្គការអន្តរជាតិហ្វ្រង់កូហ្វូនី ដោយគោរពយ៉ាងម៉ឺងម៉ាត់នូវធម្មនុញ្ញ គុណតម្លៃ និងគោលការណ៍របស់ហ្វ្រង់កូហ្វូនី ព្រមទាំងសេចក្តីសម្រេចនានារបស់ស្ថាប័នហ្វ្រង់កូហ្វូនី ឱ្យបន្តអនុវត្តសកម្មភាពដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ជាពិសេសដើម្បីជាប្រយោជន៍ដល់ប្រជាជនស៊ីវិល ;

ស៊ូដង់

83. **យើងសម្តែងនូវក្តីព្រួយបារម្ភ** ចំពោះជម្លោះដែលនៅតែបន្ត និងផលវិបាកដ៏ធ្ងន់ធ្ងរមកលើផ្នែកមនុស្សធម៌ សន្តិសុខ និងសេដ្ឋកិច្ច ដោយរួមទាំងផលវិបាកមកលើបណ្តាប្រទេសជាប់ព្រំដែន ; **យើងថ្កោលទោស** រាល់ការគាំទ្រពីក្នុងឬក្រៅប្រទេស ដែលរួមចំណែកធ្វើឱ្យជម្លោះនេះអូសបន្លាយ ;

84. **យើងអំពាវនាវ** ឱ្យមានបទឈប់បាញ់ជាបន្ទាន់ ការការពារប្រជាជនស៊ីវិល និងការធានាឱ្យជំនួយមនុស្សធម៌អាចទៅដល់អ្នកត្រូវការដោយសុវត្ថិភាព ឆាប់រហ័ស និងគ្មានការរារាំង ; យើងក៏អំពាវនាវឱ្យពង្រឹងកិច្ចខិតខំប្រឹងប្រែងនៅថ្នាក់មូលដ្ឋាន ជាតិ តំបន់ និងអន្តរជាតិ ដើម្បីដោះស្រាយជម្លោះដោយសន្តិវិធី និងជំរុញដំណើរការនយោបាយដែលគួរឱ្យជឿទុកចិត្ត មានការចូលរួមពីគ្រប់ភាគី និងមានឯករាជ្យភាព

****